ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ

វិទ្យាល័យ ហ៊ុន សែន ក្រវា

# ចូលរួមអបអរសាទរទិវាអំណាន

## លើប្រធានបទ

## បង្ហាញពីតថភាពសង្គមតាមរយៈស្នាដៃអក្សរសិល្ប៍

# រឿងកុលាបប៉ៃលិននិងរឿងផ្កាស្រពោន

**ឆ្នាំ២០១៩**


**បកស្រាយដោយ** :

លោកគ្រូ **សេក ណាន** ភេទប្រុស

ទីកន្លែងធ្វើការ : វិទ្យាល័យ ហ៊ុន សែន ក្រវ៉ា

លេខទូរស័ព្ទ : 012 23  63 13

# តថភាពសង្គមតាមរយៈស្នាដៃរឿងកុលាបប៉ៃលិននិងរឿងផ្កាស្រពោន

## សេចក្តីផ្តើម :

អក្សរសិល្ប៍គឺជាកញ្ចក់ឆ្លុះបញ្ចាំងពីតថភាពសង្គម។ អ្នកនិពន្ធស្នាដៃអក្សរសិល្ប៍គឺជាមនុស្សម្នាក់ដែលធ្លាប់បានដឹង ឬបានឮ ឬបានមើលឃើញ ឬបានឆ្លងកាត់ការរស់នៅក្នុងសង្គមសម័យកាលណាមួយជាក់ជាមិនខាន។ អ្នកនិពន្ធឬកវីគ្រប់រូបរមែងបានបញ្ចូលនូវទិដ្ឋភាព ទីកន្លែង ឬព្រឹត្តិការណ៍មួយចំនួនដែលខ្លួនបានដឹង ឬបានឮ ឬបានមើលឃើញ ឬបានឆ្លងកាត់ការរស់នៅក្នុងសង្គមណាមួយមកបញ្ចូលក្នុងវណ្ណកម្មរបស់ខ្លួនជានិច្ច។ ចំណែកឯលោក **ញ៉ុក ថែម** និងលោក **នូ ហាច**ដែលជាអ្នកនិពន្ធប្រលោមលោកទំនើបមុនដំបូងគេរបស់ខ្មែរ ក៏បានពន្លេចឱ្យឃើញនូវតថភាពក្នុងសង្គមខ្មែរយ៉ាងច្រើនដែលពួកគាត់ធ្លាប់បានឆ្លងកាត់ការរស់នៅ ឬធ្លាប់បានដឹងឮ ឬធ្លាប់បានមើលឃើញនោះតាមរយៈស្នាដៃរឿងកុលាបប៉ៃលិននិងរឿងផ្កាស្រពោន។ រឿងទាំងពីរខាងលើជាស្នាដៃអក្សរសិល្ប៍ទំនើបបែបខេមរនិយមដែលមានភាពល្បីល្បាញនិងមានប្រជាប្រិយភាពតាំងពីសម័យមុនរហូតមកដល់សព្វថ្ងៃនេះ។ ដោយសារប្រជាប្រិយភាពនិងសារៈសំខាន់នៃការឆ្លុះបញ្ចាំងរបស់រឿងទាំងពីរបែបនេះហើយទើបក្រសួងអប់រំ យុវជន និងកីឡាបានយកសាច់រឿងកុលាបប៉ៃលិននិងរឿងផ្កាស្រពោនមកបញ្ចូលក្នុងកម្មវិធីសិក្សាក្នុងសាលាចំណេះទូទៅតាំងពីសម័យមុនរហូតមកដល់សម័យបច្ចុប្បន្ននេះ។

តើរឿងកុលាបប៉ៃលិនរបស់លោក **ញ៉ុក ថែម** និងរឿងផ្កាស្រពោនរបស់លោក **នូ ហាច**បានឆ្លុះបញ្ចាំងពីតថភាពសង្គមខ្មែរនាសម័យណា? តើតថភាពសង្គមទាំងនោះមានដូចម្តេចខ្លះ? តើការឆ្លុះបញ្ចាំងពីតថភាពសង្គមទាំងនេះផ្តល់សារៈសំខាន់អ្វីខ្លះ?

## ការឆ្លុះបញ្ចាំងតថភាពសង្គម :

ដើម្បីជាជំនួយក្នុងការស្រាយបំភ្លឺនូវចំណោទបញ្ហារបស់ប្រធានបទខាងលើឱ្យបានពិស្តារ ជាបឋមគប្បីយល់ន័យរបស់ពាក្យ«តថភាពសង្គម»ជាមុនសិន។ តថភាពសង្គមគឺសំដៅយកភាពដែលមានពិតជាក់ស្តែងក្នុងសង្គមនាសម័យកាលណាមួយ។ ឬតថភាពសង្គមគឺជាទិដ្ឋភាព ឬព្រឹត្តិការណ៍ផ្សេងៗដែលកើតមានពិតនៅក្នុងសង្គមនាសម័យកាលណាមួយ។ រីឯតថភាពសង្គមខ្មែរគឺជាទិដ្ឋភាព ទីកន្លែង ឬព្រឹត្តិការណ៍ផ្សេងៗដែលមានពិត ឬកើតមានពិតក្នុងសង្គមខ្មែរនាសម័យកាលណាមួយ។ តាមន័យនេះប្រធានបទខាងលើគឺចង់ឱ្យបង្ហាញពីទិដ្ឋភាព ទីកន្លែង ឬព្រឹត្តិការណ៍

ផ្សេងៗដែលកើតមានពិតក្នុងសង្គមខ្មែរតាមរយៈស្នាដៃរឿងកុលាបប៉ៃលិនរបស់កវី **ញ៉ុក ថែម** និងរឿងផ្កាស្រពោនរបស់កវី **នូ ហាច**។

រឿងកុលាបប៉ៃលិនរបស់លោក **ញ៉ុក ថែម**គឺនិពន្ធឡើងតាំងពីឆ្នាំ១៩៣៦នៃគ.ស.ហើយរឿងផ្កាស្រពោនរបស់លោក **នូ ហាច**និពន្ធឡើងនៅឆ្នាំ១៩៤៧នៃគ.ស.។ ស្នាដៃទាំងពីរខាងលើគឺសុទ្ធតែបានតាក់តែងឡើងនៅក្នុងសម័យអាណានិគមបារាំង(១៨៦៣-១៩៥៣)ដែលប្រទេសកម្ពុជាស្ថិតក្រោមនឹមត្រួតត្រារបស់ពួកអាណានិគមបរទេសគឺប្រទេសបារាំង។ វណ្ណកម្មអក្សរសិល្ប៍ទាំងពីរខាងលើខុសពីរឿងទុំទាវរបស់**ភិក្ខុសោម**ដែលនិពន្ធនៅឆ្នាំ១៩១៥នៃគ.ស. ក្នុងសម័យអាណានិគមបារាំងតែមិនបានបង្ហាញពីតថភាពក្នុងសង្គមខ្មែរនាសម័យអាណានិគមបារាំងទេគឺបែរជាទៅពណ៌នាពីតថភាពក្នុងសង្គមខ្មែរនាសម័យលង្វែកទៅវិញ។ ចំណែករឿងកុលាបប៉ៃលិននិងរឿងផ្កាស្រពោនវិញ គឺនិពន្ធនៅសម័យអាណានិគមបារាំងហើយក៏បានរៀបរាប់ពិពណ៌នាពីតថភាពក្នុងសង្គមខ្មែរនាសម័យនោះដែរ។ តថភាពដែលរឿងទាំងពីរបានលាតត្រដាងនោះរួមមានរបបគ្រប់គ្រង ច្បាប់ ទំនៀមទម្លាប់ ប្រពៃណី ជំនឿ សាសនា ផ្នត់គំនិតមុខរបររកស៊ី មធ្យោបាយធ្វើដំណើរឬដឹកជញ្ជូន ការសិក្សាអប់រំ សន្តិសុខ ទីកន្លែង សម្បត្តិធនធានធម្មជាតិ សម្បត្តិធនធានវប្បធម៌ និងទិដ្ឋភាពនៃព្រឹត្តិការណ៍ផ្សេងៗទៀត។ ខាងក្រោមនេះជាការរៀបរាប់ពិស្តារនូវទិដ្ឋភាពផ្សេងៗដែលរឿងទាំងពីរបានឆ្លុះបញ្ចាំង៖

**១-ការឆ្លុះបញ្ចាំងពីរបបគ្រប់គ្រងដឹកនាំក្នុងប្រទេសកម្ពុជា** : របបគ្រប់គ្រងនៅទីនេះគឺសំដៅយករបបដឹកនាំ ឬបែបបទនៃរដ្ឋបាលដឹកនាំ ឬការប្រកាន់យកលទ្ធិនៃមនោគមន៍វិជ្ជានយោបាយណាមួយក្នុងការដឹកនាំគ្រប់គ្រងទៅលើប្រទេសមួយឬសង្គមមួយ។ តាមរយៈរឿងផ្កាស្រពោនគឺបានបង្ហាញយ៉ាងច្បាស់ថាប្រទេសកម្ពុជាបានស្ថិតក្រោមការគ្រប់គ្រងដឹកនាំពីពួកអាណានិគមបារាំងត្បិតរាជការបារាំងបានរៀបចំពិធីបុណ្យជាតិរបស់ខ្លួននៅថ្ងៃទី១៤ ខែកក្កដានៅលើទឹកដីប្រទេសកម្ពុជាបាន ជាពិសេសនៅទីក្រុងបាត់ដំបង។ ដូចសំដី តួអង្គចិកប៊ុន ឋនឪពុករបស់ប៊ុន ធឿនបានប្រាប់កូនគាត់នៅថ្ងៃទី១៣ ខែកក្កដាថា‹‹*ថ្ងៃស្អែក(ថ្ងៃ១៤ កក្កដា) ជាថ្ងៃបុណ្យជាតិរបស់បារាំង យើងចង់ទៅមើលបុណ្យនោះក៏ទៅចុះ*››។ ពិធីបុណ្យនេះរាជការបារាំងបានអនុញ្ញាតឱ្យមន្ត្រីរាជការនិងអ្នកធ្វើការផ្សេងៗបានឈប់សម្រាកពីមុខរបរឬកិច្ចការងារមួយថ្ងៃដើម្បីចូលរួមអបអរបុណ្យជាតិរបស់ពួកគេដូចមានការរៀបរាប់នៅទំព័រទី២៣និង២៤ថា‹‹*នៅគ្រប់ផ្លូវថ្នល់ មនុស្សឈូចរដើរមើរ មានសភាពដូចហ្វូងស្រមោច។ ពួកអ្នកស្រុកស្លៀកពាក់តាមទំនើបថ្មី។...តាមថ្នល់ក្រុងនិងតាមបង្អួចផ្ទះ ផ្សារ ទង់ជាតិបារាំង-ខ្មែរបក់យោលរោបញ្ចេញសេចក្តីសប្បាយរីករាយទៅគ្រប់ទិស។...ប៊ុន ធឿនឈរលាយឡំនឹងពពួកជន មើលទាហានកាន់អាវុធគំនាប់ងាកខ្លួនហើយឈានជើងដើរស្រុះគ្នាព្រិប ដោយមានសក្តិបីបារាំងមួយជាត់ក្រអាញជិះសេះ...ជាអ្នកបញ្ជា*››។ ឯនៅក្នុងរឿងកុលាបប៉ៃលិនវិញ ថ្វីត្បិតមិនបានបង្ហាញដោយត្រង់ដូចរឿងផ្កាស្រពោន ក៏រឿងនេះបានបង្កប់តាមរយៈបុគ្គលិកលក្ខណៈរបស់តួអង្គលោក បាឡាត់ស្រុកសង្កែ ដែលជាអ្នកគ្រប់គ្រងដឹកនាំមានអំណាចតែងមានចិត្តគំនិតមើលងាយ ជិះជាន់អ្នកក្រ អ្នកតូចទាបគ្មាន

អំណាច គ្មានបុណ្យសក្តិដូចជាការមើលងាយថៅ ចិត្រជាដើម។ ចរិតលក្ខណៈបែបនេះគឺជាចរិតលក្ខណៈរបស់មន្ត្រីខ្មែរទូទៅក្នុងសម័យអាណានិគមបារាំង។ ដូចសម្តីលោក បាឡាត់និយាយទៅកាន់ថៅចិត្រថា«*ម៉េចក៏គាត់ឯងព្រហើនម្ល៉េះក្រែងគាត់ឯងគ្រាន់តែជាអ្នកស៊ីឈ្នួលគេទេ?*»។ ចរិតបែបនេះមិនមែនមានតែលោក បាឡាត់ទេគឺមានចំពោះមន្ត្រីរាជការឬអ្នកដឹកនាំខ្មែរទូទៅផ្សេងៗទៀតនៅក្នុងសម័យអាណានិគម ដែលអ្នកធំតែងប្រកាន់ឬកពារបែបនេះដូចជាតួអង្គថៅហ្វាយស្រុក តួអង្គមេឃុំផាន់ក្នុងរឿងគូលីកំណែន តួអង្គចីសួន តួអង្គនាយឡាចក្នុងរឿងភូមិតិរច្ឆានជាដើម។

**២-ការឆ្លុះបញ្ចាំងពីទិដ្ឋភាពច្បាប់ក្នុងសង្គមខ្មែរ** : ច្បាប់គឺសំដៅយកបទបញ្ញត្តិ បទដ្ឋានគតិយុត្តិសេចក្តីបញ្ញត្តិ ក្រឹត្យក្រម ឬវិន័យដែលកំណត់ឱ្យមនុស្សគ្រប់គ្នានៅក្នុងសង្គមអនុវត្តតាម។ នៅក្នុងប្រទេសកម្ពុជានាសម័យអាណានិគមបារាំងគឺមានស្ថាប័នឬអង្គការសម្រាប់ចែងច្បាប់និងអនុវត្តច្បាប់ច្បាស់លាស់និងដាច់ដោយឡែកពីគ្នា។ ប្រការនេះខុសពីសម័យលង្វែកនិងសម័យឧដុង្គដែលការចែងច្បាប់និងអនុវត្តច្បាប់ស្ថិតនៅលើស្ថាប័នតែមួយឬបុគ្គលតែម្នាក់គឺព្រះមហាក្សត្រ។ ជាក់ស្តែងទាំងរឿងកុលាបប៉ៃលិនបានបង្ហាញពីស្ថាប័នទទួលបន្ទុកផ្នែកច្បាប់នោះច្បាស់លាស់គឺនៅត្រង់ពេលដែលលោកហ្លួងរតនសម្បត្តិបានចាត់ឱ្យមេជាវីរបស់គាត់ប្តឹងក្រសួងរាជការតាមច្បាប់អំពីហេតុចោរប្លន់ដែលកើតឡើងក្នុងគ្រួសាររបស់លោកដោយសារបក្សពួកថៅកែ ផាន់និងលោក បាឡាត់ដូចមានការរៀបរាប់នៅទំព័រទី៧៣ថា«*ដល់ព្រឹកឡើង ហ្លួងរតនសម្បត្តិ ចាត់ឱ្យមេជាវីប្តឹងក្រសួងរាជការតាមច្បាប់ អំពីហេតុចោរកម្មដែលកើតឡើងក្នុងយប់នោះសព្វគ្រប់*»។ រីឯនៅក្នុងរឿងផ្កាស្រពោនវិញក៏បានបង្ហាញពីក្រុមអយ្យការអមសាលាដំបូងខេត្តបាត់ដំបងបានកោះហៅក្រុមអ្នកដើរព្រៃនាមដែលបានកាប់ចោរពីនាក់មកស្រាយបំភ្លឺ។ ចំណុចនេះអាចបញ្ជាក់យ៉ាងច្បាស់ថានៅសម័យនោះមានសាលាជំនុំជម្រះក្តីតាម ថ្នាក់ៗ គឺថ្នាក់ខេត្តដែលហៅថាសាលាដំបូងនិងថ្នាក់ជាតិហៅថាសលាឧទ្ធរណ៍ជាដើម។ ចំណុចនេះបានបញ្ជាក់នៅទំព័រទី៨៨ថា«*ក្រោយដែលបានទទួលសំបុត្ររាយការណ៍ពីមេឃុំកំពង់ព្រះ អធិប្បាយពីដំណើរចោរប្លន់អ្នកដើរព្រៃនាមនិងអ្នកដើរព្រៃនាមបានតស៊ូហើយកាប់ចោរពីនាក់មក ក្រុមអយ្យិកាអមសាលាដំបូងខេត្តបានកោះហៅអ្នកដែលបានដើរព្រៃក្នុងគ្រានោះទាំងប៉ុន្មានដើម្បីយកមកស៊ើបសួរជាពន្លឺ*»។ ចំណុចទាំងនេះអាចបញ្ជាក់បានថាព្រះរាជាខ្មែរលែងដើរតួនាទីជាមន្ត្រីយុត្តិធម៌ឬជាចៅក្រមដូចសម័យមុនៗទៀតហើយពោលគឺរាជការបានបង្កើតឱ្យមានស្ថាប័នឬក្រសួងយុត្តិធម៌សម្រាប់ទទួលបន្ទុកលើការងារនេះច្បាស់លាស់។

**៣-ការឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃទំនៀមទម្លាប់របស់ខ្មែរ** : ទំនៀមទម្លាប់គឺជាបែបបទ សកម្មភាពឥរិយាបទ ឬកិច្ចការងារដែលតែងធ្វើតាមគ្នាតៗតាំងពីមុនរហូតមក។ ទម្លាប់របស់ប្រជាជនខ្មែរមួយក្នុងចំណោមទម្លាប់ជាច្រើនទៀតគឺឪពុកម្តាយឬអាណាព្យាបាលនៅក្នុងសង្គមខ្មែរមាន**ទម្លាប់ចែកទ្រព្យសម្បត្តិឬកេរដំណែលទុកឱ្យកូនចៅជំនាន់ក្រោយរបស់ខ្លួន**។ ឪពុកម្តាយខ្មែរភាគច្រើនតែងបម្រុងលុយកាក់ មាសប្រាក់ ដីស្រែចម្ការ ផ្ទះសំបែង ឬកេរមរតកផ្សេងៗទៀតតាមលទ្ធភាពរបស់ខ្លួនទុកសម្រាប់ចែកកូនចៅរបស់ខ្លួន។ ដោយហេតុនេះហើយទើបតួអង្គតាចឹមក្នុងរឿងកុលាបប៉ៃលិនបានពោលទៅកាន់ចៅ ចិត្រជាកូនតែមួយរបស់គាត់ មុននឹងគាត់លាចាកលោកនេះទៅថា «*កូនសំឡាញ់*

*ឪពុកទីទ័លក្រណាស់គ្មានកេរមរតកបន្តិចបន្តួចបម្រុងទុកឱ្យកូនឡើយ ដល់ឪពុកស្លាប់ទៅហើយមានតែសពនិងពាក្យបណ្ដាំទុកឱ្យកូន*»។ ចំណែកតួអង្គលោក ហ្លួងរតនសម្បត្តិក្រោយពីបានរៀបចំចាត់ចែងមង្គលការនាងឃុន នារីកូនស្រីតែម្នាក់របស់គាត់ជាមួយនឹងថៅចិត្ររួចមកក៏បានចែកមរតកជាងពាក់កណ្ដាលនៃទ្រព្យសម្បត្តិទាំងអស់ឱ្យទៅឃុន នារី និងថៅចិត្រ។ ក្រៅពីនេះមរតកខ្លះទុកចែកក្មួយតូចៗពីរបីនាក់របស់គាត់ដែលសុទ្ធតែជាក្មេងកំព្រា ដូចមានការរៀបរាប់នៅទំព័រទី៧៦ថា«...*លោក ហ្លួងរតនសម្បត្តិ ចាត់ចែងរៀបមង្គលការអាពាហ៍ពិពាហ៍រវាងនាងក្រមុំនារី បុត្រីលោកជាគូនឹងថៅចិត្រ។...ហើយលោកបានចែកមរតកឱ្យគូស្វាមីភរិយាថ្មីជាងពាក់កណ្ដាលទ្រព្យសម្បត្តិទាំងអស់របស់លោក... ហើយលោកត្រូវចែកមរតកឱ្យកូនកំព្រាទាំងនោះតាមសមគួរផង*»។ ដូចគ្នានេះដែរនៅក្នុងរឿងផ្កាស្រពោនតួអង្គយាយនួនម្ដាយវិធាវីក៏ត្រៀមបម្រុងទ្រព្យសម្បត្តិទុកចែកឱ្យកូនស្រីទោលរបស់គាត់ដែរ។ ហេតុនេះហើយទើបបានជាគាត់ពោលទៅកាន់វិធាវីថា«*នែកូន! អញមានចិត្តគិតឯងយ៉ាងបំផុត ប្រាក់កាសអញមិនមានក្រាស់ក្រែលប៉ុន្មានទេ ល្មមគ្រាន់តែទុកឱ្យឯងមិនព្រួយលំបាកថ្ងៃក្រោយប៉ុណ្ណោះ*»។ **ទម្លាម់មួយទៀតគឺទម្លាប់នៃការតាំងរូបថតជនដែលទទួលមរណៈត្រង់មុខក្ដារមឈូសឬមុខរោងបុណ្យ**។ ការនិយមយករូបថតអ្នកស្លាប់ យកតាំងនៅក្បែរមឈូសឬនៅមុខរោងនៃពិធីបុណ្យសពនេះមានតាំងពីសម័យនោះរហូតមកដល់បច្ចុប្បន្ននេះដើម្បីឱ្យញាតិជិតឆ្ងាយបានដឹងច្បាស់ថាបុគ្គលណាដែលទទួលមរណភាពនោះជានរណា។ នៅពេលវិធាវីបានលាចាកលោកទៅ គេបានយករូបថតវិធាវីមួយសន្លឹក តាំងមុខក្ដារមឈូសរបស់នាងដូចមានការរៀបរាប់នៅទំព័រទី៨៨«*នៅបាត់ដំបង គេរាប់អានតាំងរូបថតជនដែលទទួលមរណភាពមួយសន្លឹក ត្រង់មុខក្ដារមឈូស*»។ លើសពីនោះទៀត នៅក្នុងសង្គមខ្មែរពីសម័យមុននិងសម័យក្រោយតៗមកទៀតមាន**ទម្លាប់ពិសាម្លូស្លានិងបារី**ផងដែរ។ ស្ត្រីចំណាស់ៗខ្មែរចូលចិត្តទទួលទានម្លូស្លាជាប្រចាំ ហេតុនេះពេលមានភ្ញៀវមកលេងផ្ទះរមែងមានស្លាម្លូទទួលជាចាំបាច់។ ឯប្រុសៗវិញ កាលបើពេញវ័យឬមានវ័យចំណាស់បន្តិចហើយក៏មានទម្លាប់ពិសាបារីឬជក់បារីដែរ។ តាមរយៈសាច់រឿងទាំងពីរខាងលើក៏អាចឱ្យយើងមើលឃើញច្បាស់ពីទម្លាប់ទាំងពីរនេះដែរ។ នៅក្នុងរឿងផ្កាស្រពោន នៅពេលដែលយាយចាន់មកលេងផ្ទះរបស់ខ្លួន យាយនួនបានប្រាប់វិធាវីជាកូនស្រីឱ្យលើកហិបស្លាម្លូមកទទួលភ្ញៀវ ដូចមានបង្ហាញក្នុងដំណើររឿងនៅទំព័រទី៣២ថា«*ខណៈនោះ នាងវិធាវីលើកហិបស្លាមកដាក់នៅមុខភ្ញៀវ ទើបនាងលើកដៃសំពះ*»។ ដូចគ្នានេះដែរ ពេលដែលម្ដាយវិធាវីរៀបចំផ្ទះនិងបម្រុងសម្ភារៈសម្រាប់ទទួលម្ដាយណៃស៊ិតនិងចាស់ទុំមកស្ដីដណ្ដឹងវិធាវីនោះ ក៏យាយនួនឱ្យត្រៀមស្លា ម្លូ និងបារីសម្រាប់ទទួលភ្ញៀវនិងចាស់ទុំក្នុងពិធីនោះដែរ ដូចមានរៀបរាប់នៅក្នុងទំព័រទី៤០ថា«*...ឯវិធាវីនាងត្រូវវេនដុសខាត់គ្រឿងប្រាក់ស្លាបារី ជូតប៉ាន់តែនិងពែង ហើយមើលថែជួន កុំឱ្យរបស់ទាំងនោះខ្វះវត្ថុអ្វីឡើយ គឺរកកំបោរច្រកបំពេញអក រកស្លាផ្ទា ស្លាចំណិត ម្លូយ៉ាងស្រស់ៗមកបម្រុងហិបហើយដាំទឹកក្ដៅ...ឱ្យទាន់ត្រូវការ*»។ ចំណែករឿងកុលាបប៉ៃលិនវិញ ក៏បានបង្ហាញពីទម្លាប់នៃការពិសាបារីឬជក់បារីចំពោះប្រុសៗខ្មែរជាពិសេសបុរសវ័យចំណាស់និងមនុស្សប្រុសពេញវ័យ។ តួអង្គបុរសភាគច្រើនក្នុងរឿងនេះសុទ្ធតែចូលចិត្តជក់បារីដូចជាតួអង្គតាចឹម តួអង្គលោក ហ្លួងរតនសម្បត្តិ និងតួអង្គថៅ ចិត្រសុទ្ធតែមានទម្លាប់ពិសាបារី។ អ្នកនិពន្ធបានរៀបរាប់នៅទំព័រទី៩ថា«*នៅទីនោះហើយដែលជាទីឪពុកធ្លាប់មូរថ្នាំស្លឹកសង្កែពិសាជា*

*និច្ច តែឥឡូវនេះមានតែចៅ ចិត្រម្នាក់ឯង ចៅ ចិត្រអាណិតខ្លួនណាស់ ទឹកនេត្រាក៏ហូរចេញសស្រាក់ដោយឥតដឹងខ្លួន*»។ មួយវិញទៀត ពេលរថយន្តខូចតាមផ្លូវពីស្រុកសង្កែមកបប៉ៃលិនត្រូវដេកតាមផ្លូវនោះ តួអង្គចៅ ចិត្រក៏ជក់បារីនៅពេលយប់ដែរ ដូចមានការពណ៌នាថា«*មុខគួរឱ្យអនិច្ចាដល់ចៅ ចិត្រអុជបារីជក់អង្គុយកុកមើលពន្លឺភ្លើងភ្លឺះៗ តែម្នាក់ឯង ដែលភ្លើងក្នុងភ្នក់កំពុងឆេះប្រាលឆ្នោល ឯគំនិតចេះតែគិតផ្សេងៗ អណ្តែតអណ្តូង...* »។

**៤-ការឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃប្រពៃណីរបស់ខ្មែរ** : ប្រពៃណីគឺជាការងារ សកម្មភាព កិច្ចការ ឬកម្មវិធីដែលត្រូវបំពេញជាចាំបាច់ស្ទើរតែខានពុំបានគ្រប់ៗគ្នា។ ខ្មែរមានប្រពៃណីយ៉ាងច្រើនដូចជាការចែចូវស្តីដណ្តឹង ពិធីរៀបមង្គលការ ការរៀបចំពិធីបុណ្យផ្សេងៗជាដើម។ នៅក្នុងសង្គមខ្មែរបុរសនិងស្ត្រីមុននឹងរស់នៅជាប្រពន្ធប្តីត្រូវតែឆ្លងកាត់**ពិធីរៀបមង្គលការ**ដែលមានការដឹងឮពីចាស់ទុំឬឪពុកម្តាយជាមុនសិន។ ប្រពៃណីនេះខ្មែរមានតាំងពីបុរាណហូតមកដល់បច្ចុប្បន្ន។ រីឯនៅក្នុងរឿងកុលាបប៉ៃលិនវិញក៏បានបង្ហាញពីប្រពៃណីមួយនេះដែរ គឺត្រង់វគ្គអវសាននៃរឿងកុលាបប៉ៃលិនដែលលោកហ្លួងរតនសម្បត្តិបានចាត់ចែងរៀបមង្គលការអាពាហ៍ពិពាហ៍រវាងនាងឃុន នារីជាមួយនឹងចៅ ចិត្រ។ ប្រពៃណីបែបនេះក៏ឃើញមាននៅក្នុងរឿងផ្កាស្រពោនដែរ។ តួអង្គនាងថូ ម្តាយរបស់ណៃស៊ិតនិងតួអង្គយាយនួនម្តាយនាងវិធាវីបានត្រៀមរៀបចំពិធីមង្គលការរវាងណៃស៊ិតនិងវិធាវីឱ្យបានឆាប់គឺនៅខែពិសាខ។ នៅក្នុងទំព័រទី៥៦ អ្នកនិពន្ធបានរៀបរាប់ថា«*យាយនួនឃើញកូនគាត់ចេះតែមុខស្រពោនហើយស្គមថយកម្លាំងទៅៗ ដូច្នោះក៏គិតឃើញថាគួរនាំកូនគាត់ទៅលេងរំហើយចិត្ត ដោយយល់ថាការទស្សនាបុរាណដ្ឋានទាំងពួងដែលឋិតនៅក្នុងខេត្តសៀមរាបនឹងអាចនាំឱ្យកូនគាត់រីករាយសប្បាយ មានសាច់មានឈាមឡើងវិញនឹងអាលរៀបការឱ្យទាន់ខែពិសាខខាងមុខ*»។ **ប្រពៃណីមួយទៀតគឺពិធីចែចូវស្តីដណ្តឹងនិងភ្ជាប់ពាក្យ**។ ពិធីទាំងពីរនេះក៏សំខាន់ដែលខាន់មិនអាចខ្វះបានដែរនៅក្នុងសង្គមខ្មែរគឺជាកិច្ចសម្រាប់អាណាព្យាបាលឬឪពុកម្តាយខាងកូនប្រុសដែលត្រូវចាត់ចែងរកចាស់ទុំចូលចែចូវ ស៊ើបសួរខាងកូនស្រីថាទំនេរឬមិនទំនេរ ឬក៏ថាព្រមឬមិនព្រមជាដើម។ បើកាលណាស៊ើបសួរទទួលបានផលវិជ្ជមាននឹងមានពិធីស្តីដណ្តឹងភ្ជាប់ពាក្យស៊ីស្លាតែម្តង។ នៅក្នុងរឿងផ្កាស្រពោននាងថូបានពឹងយាយចាន់ជាចាស់ទុំដែលខ្លួនទុកចិត្តឱ្យមកស៊ើបសួរនាងវិធាវីពីយាយនួន។ លុះទទួលបានការយល់ព្រមពីយាយនួននាងថូក៏បានលើកចាស់ទុំមកស្តីដណ្តឹងនាងវិធាវីឱ្យណៃស៊ិតជាកូនប្រុសរបស់គាត់តែម្តង។ យាយចាន់ខ្សឹបដាក់ត្រចៀកយាយនួនថា«*ចិកណៃស៊ាន ចៅកែកាណូតដើរទន្លេ ចង់ស្តីដណ្តឹងវិធាវីឱ្យកូនប្រុសគាត់ឈ្មោះណៃស៊ិត*»។

**៥-ការឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃជំនឿរបស់ខ្មែរ** : ជំនឿគឺជាការជឿស៊ប់នឹងអ្វីមួយនាំឱ្យមនុស្សប្រកាន់ខ្ជាប់នូវឥរិយាបថ ការគិត និងការធ្វើសកម្មភាពណាមួយទៅតាមការជឿរបស់ខ្លួននោះ។ ខ្មែរមានជំនឿជាច្រើនដូចជាការជឿលើការទស្សន៍ទាយ ការជឿលើខ្មោចព្រាយបិសាច អារុក្ខអារក្ខអ្នកតា ការជឿលើការបន់ស្រន់ ការជឿលើការស្រោចទឹក ការស្តោះផ្លុំជាដើម។ ប្រជាជនខ្មែរតាំងពីបុរាណហូតមកដល់សព្វថ្ងៃនេះ បើកាលណាគាត់ចង់សម្រេចចិត្តធ្វើកិច្ចការអ្វីមួយពិបាកៗឬក៏ជួបហេតុការណ៍អ្វីមួយមិនអាចដោះស្រាយបាននោះរមែងរត់ទៅ**ពឹងលើគ្រូទស្សន៍ទាយ**ពី

ហេតុការណ៍ឬដំណើររឿងនោះឱ្យបានដឹងមុនខ្លះៗជាមិនខាន។ ចំណុចនេះបានបង្ហាញនៅក្នុងរឿងផ្កាស្រពោន គឺនៅត្រង់តួអង្គយាយនួនមុននឹងសម្រេចចិត្តលើកនាងវិធាវីកូនស្រីរបស់គាត់ឱ្យណៃស៊ិតនោះគាត់បានយកថ្ងៃខែឆ្នាំកំណើតរបស់ណៃស៊ិតនិងវិធាវីទៅឱ្យលោកគ្រូអានគង់នៅវត្តពោធិ៍ក្នុងដែលមានព្រះនាមល្បីខាងហោរាសាស្ត្រនិងមន្តអាគមស្ដោះព្រួស ទស្សន៍ទាយមើល។ ពេលដែលលោកគ្រូ អានទស្សន៍ទាយនិងចាក់គម្ពីរឃើញថាពួកគេទាំងពីរមានជោគវាសនាល្អនោះ ម្ដាយវិធាវីត្រេកអរខ្លាំងណាស់។ ដោយសារជើងលេខទស្សន៍ទាយរបស់លោកគ្រូ អាននេះហើយដែលជំរុញការសម្រេចចិត្តរបស់ម្ដាយវិធាវីព្រមលើកវិធាវីឱ្យណៃស៊ិតឥតមានអល់អែកអ្វីឡើយ។ ដូចមានការរៀបរាប់នៅទំព័រទី៣៧«*លោកគ្រូអានក៏វាយលេខ អត្តៈមួយសន្ទុះ ទើបមានសង្ឃដីកា : យីយាយ លេខប្រសើរណាស់តើ! តាំងពីអាត្មាចេះមើលហោមកពុំដែលឃើញលេខនរណាប្រកបគ្នាអីដល់ម៉្លេះ។ បើដូច្នេះ ខ្ញុំព្រះករុណាសូមផ្សងចាក់គម្ពីរមើលម្ដងទៀត*»។ ជំនឿបែបនេះក៏បានបង្ហាញម្ដងទៀតពេលវិធាវីឈឺ យាយនួនក៏បានរត់ទៅនិមន្តលោកគ្រូអានទស្សន៍ទាយម្ដងទៀតដូចមានការរៀបរាប់នៅទំព័រទី៧១និង៧២«*ព្រះសង្ឃរូបនេះ កាលបើបានពិនិត្យក្រាំងគម្ពីរនិងវាយលេខគន់គូរសព្វគ្រប់ហើយ ក៏មានសង្ឃដីកា : ញោម កូនញោមមានគ្រោះធ្ងន់។ លេខចង្កុលត្រង់ព្រះរាមត្រូវសេរផេន្ទជិត*»។ ទន្ទឹមនឹង**ការទស្សន៍ទាយនិងការចាក់គម្ពីរ**នេះក្នុងរឿងផ្កាស្រពោននេះក៏បានបង្ហាញពីជំនឿលើ**ការស្រោចទឹករំដោះគ្រោះ ការបញ្ជាន់អារក្ខ និងការបន់ស្រន់**ផងដែរ។ នៅពេលវិធាវីធ្លាក់ខ្លួនឈឺខ្លាំង យាយនួនក៏បាននិមន្តលោកគ្រូ អានមកស្រោចទឹក អញ្ជើញម៉ែអេងមកបញ្ជាន់អារក្ខ ដើម្បីបន់ស្រន់ឱ្យនាងវិធាវីបានស្រាកស្រាន្តពីជំងឺទោះបីសម័យអាណានិគមបារាំងមានទេព្យព្យាបាលជំងឺតាមបែបវេជ្ជសាស្ត្រទំនើបហើយក៏ដោយក៏**ជំនឿលើមន្តអាគមន៍**នៅតែមានដូចសម្ដីនាងថូថា«*ឱថៃ កុំរកពេទ្យ! ពេទ្យគេមើលមិនពូកែដូចគ្រូខ្មែរទេ*»។ រីឯនៅក្នុងរឿងកុលាបប៉ៃលិនវិញ លោក ហ្លួងរតនសម្បត្តិក៏**ជឿលើការទស្សន៍ទាយ** ពីព្រោះមុននឹងរៀបការឃុននារីនិងចៅចិត្រនោះគាត់ក៏បានធ្វើតាមក្បួនហោរាសាស្ត្រដែរ ដូចមានក្នុងការរៀបរាប់ក្នុងវគ្គអវសានថា«*លុះបានឫក្សពារវេលាល្អតាមឫក្សហោរាសាស្ត្រ ទើបហ្លួងរតនសម្បត្តិចាត់ចែងរៀបមង្គលការអាពាហ៍ ពិពាហ៍រវាងនាងក្រមុំនារី បុត្រីលោកជាគូនឹងចៅ ចិត្រ*»។

**៦-ការឆ្លុះបញ្ចាំងពីឥទ្ធិភាពនៃសាសនា** : សាសនាគឺជាពាក្យទូន្មាន ប្រៀនប្រដៅរបស់គ្រូអាចារ្យណាម្នាក់។ សាសនានៅលើលោកមានច្រើនដូចជាព្រាហ្មណ៍សាសនាឬហិណ្ឌូសាសនា ពុទ្ធសាសនា គ្រឹស្តសាសនា ឥស្លាមឬមូស្លីមសាសនាជាដើម។ ចំណែកនៅក្នុងសង្គមកម្ពុជា តាំងពីដើមរហូតមកដល់បច្ចុប្បន្ននេះក៏ធ្លាប់គោរពព្រាហ្មណ៍សាសនាដែរ មុននឹងទទួលយកពុទ្ធសាសនារហូតមកដល់សព្វថ្ងៃនេះ។ ហេតុនេះទោះបីប្រជាជនខ្មែរគោរពពុទ្ធសាសនាតែជំនឿមួយចំនួនរបស់ព្រាហ្មណ៍សាសនានៅតែមានវត្តមាននិងឥទ្ធិពលខ្លាំងមិនទាន់សាបរលាបឡើយ។ តាមរយៈរឿងកុលាបប៉ៃលិននិងរឿងផ្កាស្រពោនបានបញ្ជាក់យ៉ាងច្បាស់ថា**ប្រជាជនខ្មែរគោរពពុទ្ធសាសនា**។ តួអង្គ តាចឹមបានលើកយកទ្រឹស្តីរបស់ពុទ្ធសាសនាយ៉ាងច្រើនមកទូន្មាន អប់រំកូនគាត់និងខ្លួនគាត់មុនពេលគាត់លាចាកលោកទៅ។ ជាក់ស្ដែងតាចឹមបានលាន់មាត់ថា«*ឱ, ពុទ្ធោ! ពុទ្ធោ! កាលបានឮលោកគ្រូពេទ្យស្អាតសួរគាត់*»។ បន្តពីនោះតា

ចឹមក៏បានលើកឡើងនូវទ្រឹស្តីពុទ្ធសាសនាទៀតថា«...*មរណធម៌ជាសភាវៈទៀងទាត់ដែលមនុស្សសត្វទូទៅត្រូវទទួលយកនិងចៀសវាងឱ្យផុតពុំបានឡើយ*...»។ មិនត្រឹមតែប៉ុណ្ណោះតាចឹមបានលើកយកពុទ្ធភាសិតមួយឃ្លាមកផ្តាំចៅ ចិត្រជាកូនថា«*អត្តាហិអត្តនោនាថោ*»ដែលប្រែសេចក្តីថា«*ខ្លួនត្រូវទីពឹងខ្លួនតែប៉ុណ្ណោះ*»។ ដោយឡែកនៅក្នុងរឿងផ្កាស្រពោនវិញ ក៏បានបង្ហាញយ៉ាងច្បាស់ថាប្រជាជនខ្មែរគឺគោរពពុទ្ធសាសនាដែរ។ ប៉ុន្តែនៅមានលាយឡំជាមួយនឹងជំនឿមួយចំនួនក្នុងព្រាហ្មណ៍សាសនាព្រោះលោកគ្រូ អានដែលជាបុព្វជិតឬជាសាវ័កព្រះពុទ្ធបែរជាធ្វើគ្រូទស្សន៍ទាយស្តោះផ្លុំ និងស្រោចទឹករំដោះគ្រោះដើម្បីព្យាបាលជំងឺទៅវិញ។ ម្យ៉ាងវិញទៀត**ជំនឿថាសុខឬទុក្ខគឺអាស្រ័យលើពួកទេវរបស់ព្រាហ្មណ៍សាសនា**ក៏បានបង្ហាញពេលយាយនួនអញ្ជើញម៉ែអេងមកបញ្ជាន់អារក្ខដើម្បីបន់ស្រន់ឱ្យនាងវិធាវីឱ្យបានជាសះស្បើយពីជំងឺ។ ដូចមានបញ្ជាក់ក្នុងសម្តីម៉ែអេងដែលជាមេមត់ថា«*ក្មេងនេះព្រហើនណាស់ ធ្វើឱ្យខឹងណាស់! យើងខឹងណាស់! តែឥឡូវនេះ គេបានឱ្យយើងសប្បាយរួចហើយ មិនអីទេ យើងព្រមឱ្យជាបាន*... »

**៧-ការឆ្លុះបញ្ចាំងពីផ្នត់គំនិតរបស់ខ្មែរ** : ផ្នត់គំនិតគឺជាការប្រកាន់យកនូវឥរិយាបថ សកម្មភាព គំនិត ឬទស្សនៈណា ដែលគេយល់ថាមានតម្លៃ មានប្រយោជន៍ គួរតែធ្វើតាំងពីយូរលង់មកហើយ។ ការប្រព្រឹត្តខុសពីផ្នត់គំនិតអាចនាំឱ្យញាតិជិតខាងគេនិន្ទាដោយប្រការផ្សេងៗបាន។ ជនជាតិខ្មែរជាជាតិសាសន៍មួយមានផ្នត់គំនិត ជំនឿ ទំនៀមទម្លាប់ ប្រពៃណីដ៏ចំណាស់របស់ខ្លួន។ ផ្នត់គំនិតនេះគឺជាគំនិតដែលជនជាតិខ្មែរតែងជឿជាក់ហើយប្រកាន់និងអនុវត្តតាមតពូជពង្សជារៀងរហូតមក។ តាមរយៈរឿងកុលាបប៉ៃលិននិងរឿងផ្កាស្រពោននេះបានឆ្លុះបញ្ចាំងឱ្យឃើញពីផ្នត់គំនិតរបស់ប្រជាជនខ្មែរយ៉ាងច្រើន។ **ផ្នត់គំនិតដែលកូនៗត្រូវតែស្តាប់តាមឱវាទ ដំបូន្មាន ឬពាក្យប្រដៅណែនាំរបស់ឪពុកម្តាយឬអាណាព្យាបាលខ្លួន**។ ដោយហេតុនេះហើយទើបតួអង្គនាងវិធាវីមិនហ៊ានប្រកែក តវ៉ាជាមួយយាយនួនជាម្តាយនាងពេលដែលយាយនួនផ្តាច់ពាក្យនាងពីប៊ុន ធឿនហើយលើកនាងឱ្យណៃស៊ិតកូនថៅកែណៃស៊ានវិញ ទាំងដែលការសម្រេចចិត្តរបស់យាយនួននេះមិនស្របនឹងចិត្ត ឬមនោសញ្ចេតនានាងបន្តិចសោះក៏នាងមិនហ៊ានហាស្តីត្បិតទំនៀមខ្មែរតាំងពីបុរាណមកមិនដែលមានកូនណាហ៊ានប្រព្រឹត្តខុសពីការណែនាំរបស់ឪពុកម្តាយឬអាណាព្យាបាលខ្លួនឡើយ។ ស្រដៀងគ្នានេះដែរតួអង្គប៊ុន ធឿននៅពេលដែលប៊ុន ធឿន សម្រេចចិត្តចង់ឈប់រៀនដើម្បីជួយការងារគ្រួសារ ប៉ុន្តែត្រូវឪពុកខ្លួនគឺចិកប៊ុន ថនជំទាស់មិនឱ្យឈប់នោះ គឺប៊ុន ធឿនមិនហ៊ានឈប់រៀនឡើយគឺធ្វើតាមការចង្អុរបង្ហាញរបស់បិតាខ្លួន តស៊ូរៀនសូត្របន្តទោះជីវភាពខ្វះខាតក៏ដោយ។ រីឯនៅក្នុងកុលាបប៉ៃលិនវិញតួអង្គចៅ ចិត្រក៏គោរពតាមឱវាទ ដំបូន្មានរបស់តាចឹមដែលជាឪពុកខ្លួនដែរ។ មុននឹងតាចឹមបានលាចាកលោកទៅបានផ្តាំចៅ ចិត្រជាកូននូវពុទ្ធភាសិតមួយថា«*អត្តាហិអត្តនោនាថោ*» ដែលប្រែថា«*ខ្លួនជាទីពឹងរបស់ខ្លួន*»។ ចៅ ចិត្រតែងយកពាក្យទូន្មាននេះយកមកគោរពប្រតិបត្តិតាមយ៉ាងខ្ជាប់ខ្ជួននៅក្នុងដំណើរជីវិតនិងការងាររបស់ខ្លួនរហូតទទួលបានជោគជ័យ។ **ផ្នត់គំនិតនៃការរៀបចំទុកដាក់កូនចៅឱ្យមានគូស្រករតាមទ្រឹស្តីនំមិនធំជាងនាឡិ** តាំងពីសម័យបុរាណបានបន្តមានឥទ្ធិពលមកដល់សម័យអាណានិគមដែរ។ ផ្នត់គំនិតនេះគឺឪពុកម្តាយឬអាណាព្យាបានគឺជាអ្នកសម្រេចចិត្តទាំងស្រុងទៅលើការជ្រើស

រើសគូស្រករបស់កូនៗរបស់ពួកគាត់។ ហេតុនេះហើយបានជាឪពុករបស់តួអង្គវិធាវីបានភ្ជាប់ពាក្យវិធាវីនិងកូនប្រុស ចឹកប៊ុន ថនដែលជាសំឡាញ់នឹងខ្លួនគឺប៊ុន ធឿនតាំងពីវិធាវីនិងប៊ុន ធឿននៅក្មេងៗម្ល៉េះ។ ក្រោយមកទៀតពេលដែល ចឹកប៊ុន ថនបានធ្លាក់ខ្លួនក្រ យាយនួនម្ដាយវិធាវីបានផ្ដាច់ពាក្យវិធាវីពីប៊ុន ធឿនហើយលើកឱ្យណៃស៊ិតវិញដោយមិន បានសាកសួរចិត្តរបស់វិធាវីបន្តិចណាសោះហើយវិធាវីក៏មិនហ៊ានប្រកែកដែរដោយនាងយល់ថា‹‹*តាំងពីបុរាណនាយមក ស្ត្រីខ្មែរមិនមានអំណាចរើសប្ដីលើខ្លួនឯងទេ។ បើឪពុកម្ដាយទុកដាក់ល្អអាក្រក់ដូចម្ដេច ក៏ត្រូវតែទទួលយកជា និច្ច*››។ **ផ្នត់គំនិតប្រកាន់វណ្ណៈ** ទោះបីនៅក្នុងសង្គមខ្មែរមិនមានការបែងចែកវណ្ណៈជាបួនច្បាស់លាស់ដូចនៅក្នុងលទ្ធិ ព្រាហ្មណ៍ក៏ដោយ តែគំនិតប្រកាន់រើសអើងវណ្ណៈនេះ ក៏មានវត្តមានក្នុងសង្គមខ្មែរពិតប្រាកដ។ ខ្មែរក៏បានបែងចែករវាងអ្នកមាន អ្នកក្រ អ្នកឋានៈតូចទាប អ្នកឋានៈខ្ពង់ខ្ពស់ វណ្ណៈជនជាតិភាគតិច ឬអ្នកបម្រើគេជាដើម។ ដោយសារផ្នត់គំនិតប្រកាន់ រើសអើងវណ្ណៈបែបនេះហើយទើបដូនតាខ្មែរបានចងក្រងសុភាសិតមួយថា‹‹*ខ្លួនទាបកុំតោង ដៃខ្លីកុំឈោងស្រវាឱបភ្នំ*›› ។ នៅក្នុងរឿងកុលាបប៉ៃលិនតួអង្គចៅ ចិត្រតែងលើកយកសុភាសិតនេះមកដាស់តឿនខ្លួនឯងជា រឿយៗ ដើម្បីកុំ ឱ្យលង់ ចិត្តអារម្មណ៍លើយុននារីជាកូនអ្នកមានទ្រព្យសម្បត្តិស្ដុកស្ដម្ភជាងខ្លួនដែលត្រឹមជាកម្មករជីក ត្បូង។ ចំណែកតួ អង្គលោក បាឡាត់ស្រុកសង្កែក៏រើសអើងចៅ ចិត្រ ត្បិតចៅ ចិត្រជាកម្មករ ឬអ្នកស៊ីឈ្នួលគេនេះដែរ។ ដូចសម្ដីលោក បាឡាត់សួរទៅចៅ ចិត្រថា‹‹*ម៉េចក៏គាត់ឯងព្រហើនម្ល៉េះ ក្រែងគាត់ឯងគ្រាន់តែជាអ្នកស៊ីឈ្នួលគេ ទេ?*››។ ផ្នត់គំនិត បែបនេះ ក៏កើតមានចំពោះតួអង្គយាយនួនក្នុងរឿងផ្កាស្រពោនដែរ។ យាយនួនផ្ដាច់ពាក្យវិធាវីពីប៊ុន ធឿន ត្បិតគ្រួសារ ប៊ុន ធឿនធ្លាក់ខ្លួនក្រហើយលើកឱ្យណៃស៊ិត ពីព្រោះណៃស៊ិតជាកូនថៅកែណៃស៊ានជាអ្នកមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ នេះឯង។

**៨-ការឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃការងារឬមុខរបររបស់ប្រជាជនខ្មែរ** : តាមការសិក្សារឿងទាំងពីរ នេះក៏អាចឱ្យអាន អ្នកសិក្សា និងមហាជនបានឃើញយ៉ាងប្រត្យក្សថាប្រជាជនខ្មែរសម័យអាណានិគមបារាំងប្រកបកិច្ច ការងារអ្វីខ្លះដើម្បីចិញ្ចឹមជីវិត អភិវឌ្ឍគ្រួសារ និងទ្រទ្រង់សង្គមជាតិ។ **ប្រជាជនខ្មែរភាគច្រើនគឺប្រកបរបរកសិកម្ម** ឯ ប្រជាជនខ្មែរកូនកាត់ចិន ឬជនជាតិចិនដែលមករស់នៅក្នុងប្រទេសកម្ពុជាមួយចំនួនធំ តែង**ប្រកបរបរជំនួញជួញដូរ ហើយមានជីវភាពធូរធារជាងកសិករនិងមន្ត្រីរាជការ**។ ក្រៅពីមុខរបរកសិកម្មនេះប្រជាជនខ្មែរមានមុខរបរបន្ទាប់បន្សំ មួយចំនួនទៀតដូចជា**នេសាទ ចូលព្រៃដើម្បីបានអនុផលពីព្រៃឈើ**ជាដើមដើម្បីជួយផ្គត់ផ្គង់ជីវភាពបន្ថែម។ នៅក្នុង រឿងកុលាបប៉ៃលិនអ្នកនិពន្ធបានបង្ហាញពីទិដ្ឋភាពនៃស្រែចម្ការ ច្បារដំណាំរបស់ប្រជាជនយ៉ាងដេរដាសនៅតាមផ្លូវ ដែលចៅចិត្របរឡានជូនលោក ហ្លួងរតនសម្បត្តិពីស្រុកសង្កែមកបប៉ៃលិនវិញ។ ទិដ្ឋភាពនៃវាលស្រែចម្ការ ច្បារដំណាំ នេះក៏អាចបញ្ជាក់ថាប្រជាជនខ្មែរភាគច្រើននៅខេត្តបាត់ដំបងគឺប្រកបរបរកសិកម្ម។ ស្រដៀងគ្នានេះដែរនៅក្នុងរឿងផ្កា ស្រពោន អ្នកនិពន្ធក៏បានពណ៌នាពីទេសភាពវាលស្រែដែលពាសពេញតៗជាប់គ្នាដល់ជើងព្រៃដែលគេមើលទៅឃើញ ខៀវស្រងឹមនៅតាមផ្លូវពីភ្នំពេញទៅបាត់ដំបង។ ទិដ្ឋភាពនេះអាចបញ្ជាក់ថាប្រជាជនខ្មែរភាគច្រើនគឺប្រកបរបរធ្វើស្រែ

នេះហើយ។ ម៉្យាងវិញទៀតទោះបី ចឹកប៊ុន ថនឪពុកប៊ុន ធឿនជាអ្នកជំនួញដែលជួញស្រូវពីខ្មែរទៅព្រៃនគរក៏ដោយក៏ប្រពន្ធគាត់មិនចោលការងារស្រែឡើយគឺគាត់នៅតែធ្វើស្រែដូចប្រជាជនទូទៅក្នុងខេត្តបាត់ដំបងដែរ។ ចំណែកប៊ុន ធឿន វិញត្បិតរវល់តែរៀនក៏មិនភ្លេចការងារស្រែចម្ការឡើយ ពេលរាំកងធំប៊ុន ធឿនបានត្រឡប់ពីភ្នំពេញមកជួយការងារស្ទូងដកម្ដាយហើយប៊ុន ធឿនក៏ស្ទាត់នឹងការងារទាំងនោះដែរ ដូចសម្ដីម៉ែរបស់ប៊ុន ធឿននិយាយទៅកាន់នាងសោភ័ណកូនស្រីរបស់គាត់ថា«*អឺ កូនបានពីស្រែហើយ។ ប៊ុន ធឿនចេះស្ទូងរហ័សណាស់។ អ្នកផងគេតែងនិយាយថាក្មេងដែលបានទៅរៀននៅសាលាបារាំងច្រើនស្អប់ខ្ពើមការងារស្រែចម្ការ។ បងឯងនេះបានធ្វើឱ្យឃើញថានិយាយដូច្នោះជាការមិនពិតឡើយ*»។ បន្ទាប់ពីរួចការងារស្រែចម្ការនេះប្រជាកសិករមួយចំនួនបានស្វែងរកមុខរបរបន្ទាប់បន្សំមួយចំនួនទៀតដើម្បីបង្គ្រប់ ឬផ្គត់ផ្គង់ជីវភាពបន្ថែម។ ជាក់ស្ដែងនៅក្នុងរឿងផ្កាស្រពោនតួអង្គតាសូ ប៊ុន ធឿន និងអ្នកភូមិស្រុកឯទៀតប្រមាណចំនួនម្ភៃប្លាយរទេះគោបានបរចេញទៅព្រៃនាមដើម្បីនេសាទត្រីនិងរកឃ្មុំជាអាទិ៍។ ក្រៅពីមុខរបរធ្វើស្រែចម្ការនិងមុខរបរបន្ទាប់បន្សំខាងលើនេះប្រជាជនខ្មែរដែលជាកូនកាត់ចិនមួយចំនួនធំបានចាប់យក**ជំនួញជួញដូរ**ជាមុខរបររកស៊ីហើយក៏បានធ្វើឱ្យជីវភាពពួកគាត់ធូរធារច្រើនជាងអ្នកធ្វើស្រែចម្ការដែរ ដូចមានការពណ៌នានៅទំព័រទី៣ ថា«*នៅតាមមាត់ថ្នល់ទាំងសងខាងមានផ្ទះថ្ម ឬផ្ទះឈើប្រក់ក្បឿងជារបស់ចិនឬកូនចៅចិន ដែលមានរបរលក់ដូរទំនិញខោអាវ ម្ហូស្លា ទឹកត្រី ទឹកស៊ីអ៊ីវ ខ្ទឹម ម្រេច និងស្រា។ នៅខាងក្រោយឬចំហៀងគេហដ្ឋាននេះមានជង្រុកធាត់ៗ ធំៗ។ ផលទាំងពួងដែលកើតឡើងដោយញើស ដោយឈាមអ្នកស្រែទាំងនោះ តែងប្រមូលគរនៅក្នុងជង្រុកនេះ* »។ ស្រដៀងគ្នានេះដែរចឹកប៊ុន ថន និងឪពុកវិធាវី( កាលគាត់នៅរស់ ) ណៃស៊ាន និងបេងជុនដែលមានជីវភាពធូរធារនិងស្ដុកស្ដម្ភត្បិតចាប់យករបរជំនួញនេះហើយ។ ឪពុកប៊ុន ធឿន ឪពុកវិធាវី និងលោកបេងជុនសុទ្ធតែជាអ្នករកស៊ីជួញស្រូវទៅព្រៃនគរ។ រីឯណៃស៊ានដែលជាឪពុកណៃស៊ិតវិញ ក៏មានអាជីវកម្មលក់ដូរទូក កាណូតដែរ ហេតុនេះហើយទើបគ្រួសារគាត់មានឡានជិះផ្ទាល់ខ្លួននិងមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ។ លើសពីនោះទៀតលោក ហ្លួងរតនសម្បត្តិនៅក្នុងរឿងកុលាបប៉ៃលិនបានចាប់យកអាជីវកម្មជួញដូរត្បូងដែរ ទើបជាហេតុនាំឱ្យគាត់មានទ្រព្យសម្បត្តិស្ដុកស្ដម្ភជាងគេនៅបប៉ៃលិន។

**៩-ការឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃការធ្វើដំណើរនិងដឹកជញ្ជូនក្នុងប្រទេសកម្ពុជា** : ក្រឡេកមកមើលពីមធ្យោបាយធ្វើដំណើរវិញនៅក្នុងសម័យអាណានិគមបារាំងនេះប្រជាជនខ្មែរមានវិធីធ្វើដំណើរសម្បូរបែបនិងឿនលឿនជាងពីសម័យលង្វែកនិងឧដុង្គ។ កាលពីសម័យលង្វែកនិងឧដុង្គប្រជាជនខ្មែរមានមធ្យោបាយធ្វើដំណើរនិងដឹកជញ្ជូនមិនទាន់ឿនលឿនឡើយទេ គឺមិនទាន់មានគ្រឿងយន្តសម្រាប់ជាមធ្យោបាយដឹកជញ្ជូនឬធ្វើដំណើរឡើយពោលបើតាមផ្លូវគោកគឺដោយថ្មើរជើង ជិះសេះ ជិះរទេះដែលបរដោយសត្វពាហនៈដូចជាសេះ គោ និងក្របីជាដើម។ រីឯតាមផ្លូវទឹកមានទូក ក្បូន និងសំពៅដែលប្រើក្ដោង។ លុះមកដល់សម័យអាណានិគមបារាំង ជនជាតិបារាំងបាននាំមកនូវមធ្យោបាយទំនើបឱ្យប្រជាជនខ្មែរបានប្រើប្រាស់សម្រាប់ធ្វើដំណើរនិងដឹកជញ្ជូនទំនិញផ្សេងៗ ប៉ុន្តែមធ្យោបាយពីសម័យមុនក៏នៅមានវត្តមានមួយចំនួនដែរមិនទាន់បាត់បង់ទាំងស្រុងឡើយ។ នៅសម័យអាណានិគមបារាំងប្រជាជន

ខ្មែរងាកមកប្រើរ៉ឺម៉ក រថយន្តតូច រថយន្តធំ រថភ្លើង កប៉ាល់មួយចំនួនធំព្រោះវាផ្តល់ភាពងាយស្រួល ចំណេញពេលវេលា មានផាសុកភាព និងសុខសុវត្ថិភាពផង។ ជាក់ស្តែងនៅក្នុងរឿងកុលាបប៉ៃលិនគ្រួសារលោក ហ្លួងរតនសម្បត្តិមានរថយន្តជិះផ្ទាល់ខ្លួនហើយមានជួលអ្នកបើកបរទៀតផងគឺតាសុននិងថៅ ចិត្រ។ នៅទំព័រទី២៤អ្នកនិពន្ធបានរៀបរាប់ថា ‹‹*លុះដល់ព្រឹកឡើងថៅ ចិត្រក៏លីចបដើរចេញទៅធ្វើការជីកត្បូងនាអណ្តូងត្បូងត្រង់ទិសខាងកើត ដូចសព្វដងដែលធ្លាប់ធ្វើមករាល់ៗថ្ងៃ បានដើរកាត់មុខផ្ទះធំនោះទៅ ស្រាប់តែឃើញនាងនារីនិងលោក ហ្លួងរតនសម្បត្តិអង្គុយក្នុងរថយន្តឃីហោរីណូត៍...ឯតាសុនជាអ្នកបើកបររថយន្តនោះ ខំប្រឹងរវៃទាល់តែបែកញើស...*››។ ម្យ៉ាងវិញទៀតនៅក្នុងរឿងផ្កាស្រពោនពេលប៊ុន ធឿនធ្វើដំណើរពីភ្នំពេញមកបាត់ដំបងគឺជិះរថភ្លើង។ បន្ទាប់ពីចុះពីរថភ្លើង  ប៊ុន ធឿនក៏បន្តជិះរ៉ឺម៉កពីស្ថានីយ៍ទៅផ្ទះខ្លួនទៀត។ ដូចមានការរៀបរាប់នៅទំព័រទី៥‹‹*ហ្វ្រាំងស្រែករថភ្លើងក៏ឈប់ទន្ទឹមនឹងស្ថានីយ៍...ប៊ុន ធឿនទាញមួកមកពាក់ កញ្ចក់វ៉ាលីរបស់ខ្លួនមកកាន់ ចាប់ដៃលាពួកម៉ាកពីរបីនាក់ ហើយក៏ញែកពពួកមនុស្សដើរតំរង់ទៅអ្នកចាំទ្វា...រួចក៏ឡើងជិះក្នុងរ៉ឺម៉កមួយ...*››។ ចំណែកគ្រួសារណៃស៊ានឪពុកណៃស៊ុតប្រកបរបរលក់កាណូតហើយមានឡានជិះផ្ទាល់ខ្លួនផងដែរ។ នាងថូម្តាយណៃស៊ុតជានាឱ្យគេបើកឡានផ្ទាល់ខ្លួនគាត់ជូនយាយនួននិងវិធាវីទៅលេងសៀមរាបថា‹‹...*ចាំឱ្យគេបើកទានតូចខ្ញុំជូនទៅ! កុំជិះឡានឈ្នួលធ្វើអី វាពិបាកណាស់*››។ ទោះបី ជាមានមធ្យោបាយទំនើបដូចរៀបរាប់ខាងលើ ប៉ុន្តែមិនទាន់ទូលំទាយទូទាំងប្រទេសឡើយ ត្បិតរទេះគោក្របី និងរទេះសេះក៏នៅតែដើរសំខាន់សម្រាប់ជាមធ្យោបាយធ្វើដំណើរនិងដឹកជញ្ជូនសម្រាប់ប្រជាកសិករនិងអ្នកមានជីវភាពក្រីក្រ។ ចំណុចទាំងនេះបានបង្ហាញនៅត្រង់ពេលដែលតាសូ ប៊ុន ធឿន និងអ្នកភូមិមួយចំនួនទៀតទៅព្រៃរនាមគឺជិះរទេះដែលបរដោយសត្វគោក្របី។ ម្យ៉ាងវិញទៀតពេលយាយនួននិងវិធាវីធ្វើដំណើរពីផ្ទះលោកបេងផុនទៅមើលប្រាសាទវង់តូចគឺជិះរទេះសេះ។

លោកបេងផុននិយាយទៅកាន់យាយនួនថា‹‹...*ណ្ហើយស្អែកនេះ ថៃអញ្ជើយរទេះសេះមើលវង់តូចសិនចុះ។ ចំណែកខ្ញុំនឹងនៅខំធ្វើឡានឱ្យរួចទាន់ខានស្អែកនេះ ដើម្បីជូនថៃមើលវង់ធំ បន្ទាយស្រី ហើយប្រសិនជាមានពេលយើងទៅដល់ភ្នំគូលែនម្តង*››។

**១០-ការឆ្លុះបញ្ចាំងពីផិជ្ជភាពនៃការសិក្សាអប់រំក្នុងសង្គមខ្មែរ** : ការសិក្សាអប់រំប្រជាជនខ្មែរងាកមកឱ្យតម្លៃការសិក្សាតាមសាលាទំនើបរបស់បារាំងវិញពោលគឺមិនសូវបញ្ជូនកូនឱ្យបួសរៀននៅតាមវត្តដូចសម័យមុនៗឡើយ។ រាជការបារាំងបានបង្កើតឱ្យមានបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យសម្រាប់កុមារនិងយុវជនខ្មែរបានសិក្សារៀនសូត្រឱ្យមានចំណេះ ជំនាញពិតប្រាកដតាមបែបវិទ្យាសាស្រ្តដែលមានកម្មវិធីសិក្សាច្បាស់លាស់និងមានសាស្ត្រាចារ្យដែលមានគរុកោសល្យពិតប្រាកដ។ តួអង្គលោកគ្រូពេទ្យស្អាតបានសិក្សារៀនសូត្រក្នុងសាលាទំនើបរបស់បារាំងនេះហើយទើបមានចំណេះ ជំនាញពេទ្យច្បាស់លាស់។ រីតួអង្គថៅចិត្រវិញក៏បានរៀន សូត្រក្នុងសាលារបស់បារាំងដែរទើបថៅចិត្រមានចំណេះអាចការពារខ្លួនឱ្យរួចផុតពីជំងឺគ្រុនចាញ់នៅបប៉ៃលិនបាន។ មួយវិញទៀតនៅក្នុងរឿងផ្កាស្រពោនតួអង្គប៊ុន ធឿននិងមិត្តភក្តិរបស់គេមួយចំនួនទៀតដូចជាបូណាជាដើមសុទ្ធតែជាសិស្សវិទ្យាល័យព្រះ

ស៊ីសុវត្ថិដែលជាសាលាទំនើបមួយនៅក្នុងសម័យអាណានិគមបារាំងសម្រាប់បណ្តុះបណ្តាលកូនខ្មែរឱ្យមានចំណេះជំនាញផ្សេងៗអាចធ្វើការតាមជំនាញនីមួយៗបានជាពិសេសការងាររាជការ។ ដូចសម្តីម្តាយប៊ុន ធឿននិយាយទៅកាន់នាងសោភ័ណជាកូនថា«*...ប៊ុន ធឿនចេះស្ទួងហើសណាស់។ អ្នកផងគេតែងនិយាយថាក្មេងដែលបានទៅរៀននៅសាលាបារាំងច្រើនស្អប់ខ្ពើមការងារស្រែចម្ការ*»។

**១១-ការឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃសន្តិសុខក្នុងសង្គមខ្មែរ** : ចំពោះបញ្ហាសន្តិសុខសង្គមវិញ នៅសម័យអាណានិគមបារាំងគឺមានចោរកម្មនិងអសន្តិសុខច្រើន ហើយពួកចោរមានអាវុធទំនើបៗទៀតផងគឺប្រើសុទ្ធតែកាំភ្លើងទៀត។ គ្រាន់តែនៅក្នុងរឿងកុលាបប៉ៃលិនមួយ អ្នកនិពន្ធបានបង្ហាញពីសកម្មភាពចោរប្លន់ដល់ទៅពីរដង។ លើកទីមួយគឺចោរប្លន់លោក ហ្លួងរតនសម្បត្តិនៅតាមផ្លូវពីស្រុកសង្កែមកបប៉ៃលិនវិញហើយបាញ់ចៅចិត្រឱ្យមានរបួសទៀតផង។ ដូច មានក្នុងសម្តីចៅចិត្រស្រែកប្រាប់យុននារីថា«*ខ្ញុំត្រូវគ្រាប់របស់ចោរហើយយុននារី! ស្រែកថ្ងូរតែក្នុងបំពង់ក ហើយមានឈាមហូរចេញពីខ្លួនក្រហមច្រាល...*»។ លើកទីពីរគឺក្រុមចៅកែផាន់និងលោកបាឡាត់បានមកប្លន់ត្បូងលោក ហ្លួងរតនសម្បត្តិដល់ផ្ទះតែម្តងហើយក៏មានកាំភ្លើងដែរ។ ដូចមានក្នុងការរៀបរាប់របស់អ្នកនិពន្ធនៅទំព័រទី៦៩ថា«*ការតស៊ូរវាងពួកចោរនិងកម្មករសុទ្ធតែមានអាវុធគ្រប់ដៃទាំងសងខាងកាន់តែខ្លាំងឡើងៗដល់ថ្នាក់ប្រឡូកគ្នាមិនគិតស្តាយជីវិតរៀងខ្លួន...*»។ ស្រដៀងគ្នានេះដែរនៅក្នុងរឿងផ្កាស្រពោន អ្នកនិពន្ធក៏បានបង្ហាញពីក្រុមចោរប្លន់ប្រហែលម្ភៃនាក់ប្រដាប់ដោយកាំភ្លើងមកបាញ់ប្លន់គោ ក្របី និងទ្រព្យសម្បត្តិរបស់តាសូ ប៊ុន ធឿន តាប្រាក់ និងអ្នកភូមិផ្សេងៗទៀតនៅឯព្រៃនាមផងដែរ។ នៅទំព័រទី៨៤អ្នកនិពន្ធបានពណ៌នាថា«*មានយប់មួយ នៅពេលវិលែងអធ្រាត្រអ្នកដើរព្រៃកំពុងដេកលក់ស្រមុកយ៉ាងក្សេមក្សាន្ត ស្រាប់តែសូរកាំភ្លើងបាញ់បីដងព្រមទាំងមាត់មនុស្សចំនួនប្រហែលម្ភៃនាក់ស្រែកហ៊ោយកជ័យ...តាប្រាក់ភ្ញាក់ឡើងដឹងថាមានចោរប្លន់ ក៏ប្រមូលពួកកងគាត់កាន់ខ្សែ កាន់ដាវ កាន់ពូថៅហើយរត់ចូលព្រៃអស់...*»។ ចំណុចទាំងនេះអាចបញ្ជាក់ថាប្រជាជនខ្មែរនៅសម័យណានិគមបារាំងរស់នៅដោយភាពភ័យខ្លាចនឹងបញ្ហាចោរកម្មនិងបញ្ហាអសន្តសុខទាំងនេះយ៉ាងខ្លាំង។

**១២-ការឆ្លុះបញ្ចាំងពីទីកន្លែងក្នុងប្រទេសកម្ពុជា** : រឿងកុលាបប៉ៃលិននិងរឿងផ្កាស្រពោនបានរៀបរាប់ពីឈ្មោះទីកន្លែងដែលមានពិតប្រាកដនៅក្នុងប្រទេសកម្ពុជា ដែលអាចជាផ្នែកមួយនៃមេរៀនភូមិសាស្ត្រនិងប្រវត្តិសាស្ត្រផងដែរ។ គ្រាន់តែឮរឿងកុលាបប៉ៃលិន ក៏អាចដឹងថារឿងនេះបង្ហាញពីទិដ្ឋភាពនៅឯណាដែរ។ រឿងកុលាបប៉ៃលិនបញ្ជាក់យ៉ាងច្បាស់នាសម័យនោះប៉ៃលិនមិនមែនជាខេត្តដូចបច្ចុប្បន្ននេះឡើយ។ ប៉ៃលិនឬបប៉ៃលិនគឺគ្រាន់តែស្រុកមួយក្នុងខេត្តបាត់ដំបងតែប៉ុណ្ណោះ។ ដូចមានភ័ស្តុតាងបញ្ជាក់ក្នុងសម្តីលោកគ្រូពេទ្យស្អាតប្រាប់ទៅចៅចិត្រថា«...*ការដែលឯងត្រូវធ្វើនោះ មិនមែននៅក្នុងទីនេះទេ គឺនៅឯស្រុកបប៉ៃលិនឯណោះ*»។ ក្រៅពីទីកន្លែងនេះអ្នកនិពន្ធក៏បានរៀបរាប់ពីទីកន្លែងមួយចំនួនទៀតដូចជាផ្សារវិល បាត់ដំបង និងស្រុកសង្កែជាដើម។ ចំណែកនៅក្នុងរឿងផ្កាស្រពោនវិញក៏បានរៀបរាប់ពីទីកន្លែងពិតប្រាកដជាច្រើននៅក្នុងប្រទេសកម្ពុជាដែរជាពិសេសនៅក្នុងខេត្តបាត់ដំបង។ ទីកន្លែង

ទាំងនោះដូចជាទីក្រុងភ្នំពេញ វិទ្យាល័យព្រះស៊ីសុវត្ថិ ភូមិកំពង់ព្រះ ដំណាក់អូរដំបង ស្ពានដែកបាត់ដំបង វត្តកណ្ដឹង ផ្លូវជាតិលេខ៥ អន្លង់វិល ជ្រនីក ស្វាយកង់ ភូមិពោធិ៍ ស្ទឹងសង្កែ និងខេត្តសៀមរាប។ ដូចមានការពណ៌នានៅក្នុងរឿងផ្កាស្រពោនទំព័រទី៥៤ថា«...*ស្ទឹងសង្កែនៅរដូវប្រាំង តែងតែរីងស្រកស្ទើរអស់នៅសល់តែខ្សែទឹកតូចៗតាមប្រឡោះកូនកោះខ្សាច់ដុះឡើងក្នុងផ្ទៃនៃផ្លូវទឹក...*»។ ឯនៅទំព័រទី៦០អ្នកនិពន្ធបានរៀបរាប់ថា«*សៀមរាបជាកូនក្រុង មួយស្អាតញញឹម លំអដោយថ្នល់ដែលមានរុក្ខជាតិចោលម្លប់ទៅលើត្រឈឹងត្រឈៃ*»។

**១៣-ការឆ្លុះបញ្ចាំងពីទិដ្ឋភាពធនធាននៃសម្បត្តិធម្មជាតិក្នុងប្រទេសកម្ពុជា** : ប្រទេសកម្ពុជាគឺជាប្រទេសដែលសម្បូរទៅដោយសម្បត្តិធនធានធម្មជាតិយ៉ាងច្រើនដូចជាព្រៃព្រឹក្សា លតាវល្លិ ស្ទឹង ទន្លេ បឹង បួរ សមុទ្រដែលផ្ដល់នូវមច្ឆា បក្សាបក្សី ម្រឹគតូចធំ ឃ្មុំ និងភោគទ្រព្យរ៉ែដ៏មានតម្លៃមហិមាផ្សេងៗទៀត។ អ្នកនិពន្ធរឿងកុលាបប៉ៃលិននិងអ្នកនិពន្ធរឿងផ្កាស្រពោនក៏បានពន្លេចឱ្យឃើញនូវភោគទ្រព្យទាំងនេះដូចៗគ្នា។ លោក **ញ៉ុក ថែម** បានពណ៌នាពី**ភោគទ្រព្យរ៉ែត្បូងនៅបប៉ៃលិន**ដោយសារទឹកដីប៉ៃលិនសម្បូរធនធានត្បូងបែបនេះហើយទើបលោក ហ្លួងរតនសម្បត្តិប្រកបរបរអាជីវកម្មជីកត្បូង។ ត្បូងនៅប៉ៃលិនមានសោភ័ណភាពល្អប្រណិតនិងមានតម្លៃថ្លៃៗណាស់។ ដូចមាននៅក្នុងទំព័រទី៥៩នៃរឿងនេះអ្នកនិពន្ធបានពណ៌នាថា«*ចៅកែផាន់និងលោកបាឡាត់បើកថ្កែកគ្រលួងកាលដែលបានឃើញត្បូងពណ៌ផ្សេងៗក្នុងហឹបនេះមានចំនួនដល់ទៅជាង២០០គ្រាប់។ ចៅកែផាន់ចាប់ត្បូងលើកឡើងពិនិត្យមើលដោយប្រុងប្រយ័ត្នហើយដាក់ទៅវិញដោយនិយាយថាត្បូងអស់នេះទឹកល្អមែន ប្រហែលជាមានតម្លៃច្រើន ?*»។ ចំណែក លោក **នូ ហាច**វិញក៏បានពណ៌នាពីធនធានមួយចំនួនក្នុងស្នាដៃរឿងផ្កាស្រពោនដែរ។ គាត់បានបង្ហាញពី**ធនធានមច្ឆា ឃ្មុំ និងសត្វម្រឹគដូចជំរីជា**ដើម។ ពេលតាសូ ប៊ុន ធឿន និងអ្នកភូមិផ្សេងៗទៀតទៅព្រៃរនាម។ នៅព្រៃរនាមតាមបឹងត្រពាំង ប្រឡាយសម្បូរត្រីណាស់ ឯតាមព្រៃវិញសម្បូរឃ្មុំណាស់ដែរ។ ព្រៃនេះក៏សម្បូរសត្វជំរីដែរ។ ដូចមានការពណ៌នានៅទំព័រទី៨២ថា«*ពួកអ្នកដើរព្រៃកាលបើបានសង់ជំរំរួចស្រេចហើយ ក៏ចាត់បំបែកគ្នាជាបីកង។ មួយកងអ្នកដើររកឃ្មុំ យកកូន ក្រមួន និងទឹក។ មួយកងទៀតជាអ្នកស្វែងនេសាទត្រីតាមបឹង តាមត្រពាំង...*»។

**១៤-ការឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃសម្បត្តិវប្បធម៌ខ្មែរ** : បុព្វបុរសដូនតាខ្មែរតាំងពីសម័យនគរភ្នំមកបានបន្សល់ទុកនូវសម្បត្តិវប្បធម៌ច្រើនឥតគណនាជាពិសេសប្រាង្គប្រាសាទបុរាណខ្មែរ ដែលជាស្នាដៃស្ថាបត្យកម្មដ៏កំពូលដែលពិភពលោកទទួលស្គាល់និងកោតស្ញប់ស្ញែង។ តាំងពីសម័យនគរភ្នំមកដល់សម័យអង្គរដូនតាខ្មែរបានកសាងប្រាសាទបុរាណរាប់ពាន់ប្រាសាទ។ ប្រាសាទទាំងនេះមានមួយចំនួនបានខូចបាក់បែកខ្ទេចខ្ទី តែមួយចំនួនទៀតនៅឈរយ៉ាងរឹងមាំរហូតដល់បច្ចុប្បន្ននេះ។ ក្នុងចំណោមប្រាង្គប្រាសាទទាំងអស់របស់ខ្មែរ ប្រាសាទអង្គរគឺជាប្រាសាទមួយដែលមានសោភ័ណភាពល្អលើសគេហើយក៏រឹងមាំជាងគេ ទោះបីមានអាយុកាលរាប់ពាន់ឆ្នាំហើយក៏ដោយ។ មិនថាជនជាតិខ្មែរឬជនជាតិបរទេសនោះទេ រមែងប្រាថ្នាចង់ទស្សនាផ្ទាល់នូវប្រាង្គប្រាសាទនានានៅតំបន់អង្គរទាំងនេះ។ ដោយហេតុនេះហើយទើបលោក **នូ ហាច** បានពន្លេចឱ្យឃើញនូវទេសភាពនិងសោភ័ណភាពនៅតំបន់ប្រាង្គប្រាសាទ

ទាំងនេះដែលប្រៀបបាននឹងពួកទេវៈនាឋានសួគ៌និមិតឡើង។ មិនថាជនជាតិខ្មែរឬជនបរទេសទេ កាលបើបានមកទស្សនានូវទេសភាពនិងសោភ័ណភាពដ៏ល្អវិចិត្រទាំងនេះហើយតែងបានស្រាកស្រាន្តធូរស្បើយអស់នូវទុក្ខកង្វក់ដែលមានទាំងប៉ុន្មាន។ ជាក់ស្ដែងពេលដែលនាងវិជាវីធ្លាក់ខ្លួនស្គមស្គាំងរីងរៃម្ដាយនាងបានជូននាងមកលេងប្រាសាទបុរាណខ្មែរនៅខេត្តសៀមរាបពិសេសប្រាសាទអង្គរវត្តតែម្ដង។ ត្បិតយាយនួនយល់ថាទិដ្ឋភាពនិងទេសភាពនៃប្រាសាទបុរាណខ្មែរទាំងនេះនឹងអាចជួយឱ្យកូនស្រីរបស់គាត់បានសប្បាយចិត្តនិងស្រាកស្រាន្តធូរស្បើយពីជំងឺផ្លូវចិត្តមួយនេះ។ ដូចមានការពណ៌នារបស់អ្នកនិពន្ធនៅក្នុងទំព័រទី៥៥និង៥៦ថា«*យាយនួនឃើញកូនគាត់ចេះតែមុខស្រពោន ហើយស្គមថយកម្លាំងទៅៗ ដូច្នោះក៏គិតឃើញថាគួរនាំកូនគាត់ទៅលេង រំហើយចិតដោយយល់ថា ការទស្សនាបុរាណដ្ឋានទាំងពួងដែលឋិតនៅក្នុងខេត្តសៀមរាបនឹងអាចនាំឱ្យគាត់រីករាយសប្បាយ មានសាច់មានឈាមឡើងវិញ...*»។

សរុបសេចក្ដីមករឿងកុលាបប៉ៃលិននិងរឿងផ្កាស្រពោនគឺជាស្នាដៃដែលបានតាក់តែងឡើងនៅក្នុងសម័យដែលប្រទេសកម្ពុជាស្ថិតក្រោមនឹមត្រួតត្រាបារាំងឬសម័យអាណានិគមបារាំង។ វណ្ណកម្មទាំងពីរនេះបានឆ្លុះបញ្ចាំងតថភាពក្នុងសង្គមខ្មែរនាសម័យនោះយ៉ាងច្រើនដូចជា ៖ របបគ្រប់គ្រង ច្បាប់ ទំនៀមទម្លាប់ ប្រពៃណី ជំនឿ សាសនា ផ្នត់គំនិត មុខរបររកស៊ី មធ្យោបាយធ្វើដំណើរឬដឹកជញ្ជូន ការសិក្សាអប់រំ សន្តិសុខ ទីកន្លែង សម្បត្តិធនធានធម្មជាតិ សម្បត្តិធនធានវប្បធម៌ ដែលអាចយកទុកមេរៀនប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និងចិត្តសាស្ត្រខ្លះៗក៏សឹងតែបាន។

## **សេចក្ដីសន្និដ្ឋាន** :

ឆ្លងតាមការសិក្សានិងវិភាគខាងលើរួចមកអាចសន្និដ្ឋានបានថាលោក **ញ៉ុក ថែម** និងលោក **នូ ហាច**គឺជាអ្នកនិពន្ធដែលបានបើកពន្លឺផ្លូវនៃស្នាដៃអក្សរសិល្ប៍ទំនើបបែបខេមរនិយមតាមរយៈស្នាដៃរឿងកុលាបប៉ៃលិននិងរឿងផ្កាស្រពោនរបស់គាត់សម្រាប់អ្នកនិពន្ធឬកវីខ្មែរក្រោយៗទៀតរៀនសូត្រតាម។ មិនត្រឹមតែប៉ុណ្ណោះទេ វណ្ណកម្មអក្សរសិល្ប៍ទាំងពីរនេះបានចូលរួមចំណែកក្នុងថែរក្សានិងផ្សព្វផ្សាយនូវវប្បធម៌-អរិយធម៌ខ្មែរដែលជាអត្តសញ្ញាណជាតិខ្មែរផងដែរ។ ទន្ទឹមនឹងនេះ រឿងទាំងពីរនេះក៏បានដើរតួស្របនឹងនិយមន័យនិងមុខងាររបស់អក្សរសិល្ប៍ពោលគឺ«*អក្សរសិល្ប៍ជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងនូវតថភាពសង្គម*»។ លើសពីនេះទៅទៀតរឿងកុលាបប៉ៃលិននិងរឿងផ្កាស្រពោនគឺជាស្នាដៃដែលបង្ហាញពីតម្លៃពិសេសរបស់ជាតិខ្មែរ ដែលខុសប្លែកពីបរទេសតាំងពីជំនឿ ទំនៀមទម្លាប់ ប្រពៃណី ទស្សនៈចិត្តគំនិត និងអាកប្បកិរិយាផ្សេងៗរបស់ខ្មែរ។ យើងអាចនិយាយបានថារឿងទាំងពីរនេះជួយទ្រទ្រង់ព្រលឹងជាតិខ្មែរឱ្យស្ថិតស្ថេរជាអមតៈ។

ទោះបីជាការសិក្សាវិភាគក្នុងអត្ថបទខាងលើរបស់ខ្ញុំ ខ្ញុំបាទបានព្យាយាមបកស្រាយពីតថភាពយ៉ាងច្រើនក្នុងសង្គមខ្មែរពីក្នុងស្នាដៃទាំងពីរនេះយ៉ាងណាក៏ដោយ ក៏គង់នៅមានចំណុចខ្វះចន្លោះ ឬឆ្គាំឆ្គងដោយសារចំណេះដឹងលើការប្រើប្រាស់ពាក្យពេចន៍ ឃ្លាប្រយោគ ឬល្បះ និងសមត្ថភាពនៃការវិភាគនៅមានកម្រិតនៅឡើយ ហើយម្យ៉ាងទៀតនេះក៏ជាស្នាដៃថ្មីថ្មោងរបស់ខ្ញុំបាទដែរ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្ដី ខ្ញុំក៏សង្ឃឹមថាអត្ថបទនៃការសិក្សាវិភាគខាងលើនេះ

អាចចូលរួមចំណែកក្នុងការបង្ហាញនិងលើកស្ទួយនូវទេពកោសល្យរបស់កវី និពន្ធខ្មែរជំនាន់មុនៗបានមួយផ្នែកដែរ។ ខ្ញុំបាទរីករាយក្នុងការទទួលយកនូវការរិះគន់ដើម្បីស្ដាបនានានាពីរៀមច្បងនិងអ្នកចេះដឹងគ្រប់មជ្ឈដ្ឋានជានិច្ច។

## ឯកសារពិគ្រោះ


1. វចនានុក្រមខ្មែរ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យឆ្នាំ១៩៦៧គ.ស.
2. រឿងកុលាបប៉ៃលិន និពន្ធដោយលោក **ញ៉ុក ថែម** បោះពុម្ពដោយគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយនៃក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០០៣គ.ស.
3. រឿងផ្កាស្រពោន និពន្ធដោយលោក **នូ ហាច** បោះពុម្ពដោយគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយនៃក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០០៣គ.ស.
4. អត្ថបទ«តម្លៃសកលរបស់ស្នាដៃអក្សរសិល្ប៍រឿងទុំទាវ»របស់លោក **ណន ម៉ារ៉ាឌី** ម្ចាស់ជ័យលាភីចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៨
5. អក្សរសាស្ត្រខ្មែរថ្នាក់ទី១២ បោះពុម្ពដោយគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយនៃក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០១៤គ.ស.
6. អក្សរសាស្ត្រខ្មែរថ្នាក់ទី១១ បោះពុម្ពដោយគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយនៃក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០១០គ.ស.
7. ភាសាខ្មែរថ្នាក់ទី១០ បោះពុម្ពដោយគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយនៃក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១០គ.ស.
8. Santepheapdaily.com.kh
9. www.wikipedia.org>wiki>រឿងផ្កាស្រពោន
10. www.wikipedia.org>wiki>រឿងកុលាបប៉ៃលិន
11. https://m.youtube.com( ល្ខោននិយាយរឿងកុលាបប៉ៃលិន )ដែលប្រែសម្រួលដោយលោក **ពេជ្រ ពណ្ណរាយ** ដែលសម្ដែងដោយក្រុមសិល្បៈវិទ្យុជាតិកម្ពុជា
12. https://m.youtube.com( ល្ខោននិយាយរឿងផ្កាស្រពោន )ដែលប្រែសម្រួលដោយលោក **ពេជ្រ ពណ្ណរាយ** ដែលសម្ដែងដោយក្រុមសិល្បៈវិទ្យុជាតិកម្ពុជា



**បកស្រាយដោយ** :

លោកគ្រូ **សេក ណាន** ភេទប្រុស

ទីកន្លែងធ្វើការ : វិទ្យាល័យ ហ៊ុន សែន ក្រវ៉ា

លេខទូរស័ព្ទ : 012 23  63 13